ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥០៦ សហវ.៣៥

# ប្រកាស

ស្ដីពី

## ការប្រើប្រាស់ទម្រង់លិខិតប្រកាស បង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ០២-នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤ និងព្រះរាជក្រម លេខ ០៨-នស-៩៤ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រម លេខ ១១-នស-៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និងព្រះរាជក្រម លេខ ជស-រកម-០៩៩៥-០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ ការគ្រប់គ្រង ឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រម លេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញប្រកាសលេខ ០៥៥ ប្រក.សហវ.ពដ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៥ ស្ដីពីគោលការណ៍ជាមូលដ្ឋានសំរាប់អនុវត្តការប្រមូលពន្ធលើប្រាក់ចំណេញ
- បានឃើញប្រកាសលេខ ៥៣៥ ប្រក.សហវ.ពដ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០០ ស្ដីពីគោលការណ៍ជាមូលដ្ឋានសំរាប់អនុវត្តការប្រមូលពន្ធលើប្រាក់ចំណេញ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ ។

## សម្រេច :

**ប្រការ ១.-** ដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់ស្តីពីសារពើពន្ធ សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិត ក្នុងនោះមានទាំងសហគ្រាសវិនិយោគដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ១ ភាគរយ នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករគ្រប់ប្រភេទដែលសម្រេចបានក្នុងខែមុន ។ ប្រាក់រំដោះនេះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញ នៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ ។

**ប្រការ ២.-** ដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃមាត្រា៣៨ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងករណីដែលសហគ្រាសមានបំណុលពន្ធលើប្រាក់ចំណេញតិចជាងប្រាក់រំដោះដែលបានបង់ប្រចាំឆ្នាំ ចំនួនលំអៀងនឹងត្រូវបានអនុញ្ញាតឱ្យយោងទៅប្រើប្រាស់ជាឥណទានសម្រាប់កាត់កងនឹងប្រាក់រំដោះត្រូវបង់ក្នុងឆ្នាំខាងមុខ ឬស្នើសុំបង្វិលសងវិញប្រសិនបើសហគ្រាសបញ្ឈប់សកម្មភាពអាជីវកម្ម ។ ការស្នើសុំយោងជាឥណទាន ឬស្នើសុំបង្វិលសង ត្រូវធ្វើឡើងតាមរយៈលិខិតប្រកាសបង់ប្រាក់រំដោះប្រចាំខែ ។

**ប្រការ ៣.-** នាយកដ្ឋានពន្ធដារ ត្រូវកំណត់នូវទម្រង់លិខិតប្រកាសបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងប្រការ២ ខាងលើនេះ ។

**ប្រការ ៤.-** ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០២

គាត ឈន់

**ចម្លងជូន :**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ ។